ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌

អត្ថបទស្រាវជ្រាវអំពី

# ក្រមាខ្មែរ

ឆ្នាំ២០១៧

## ១. សេចក្ដីផ្ដើម

ខ្មែរយើងមិនពិបាកយល់ឡើយថាអ្វីជា “ក្រមា” ដ្បិតរបស់នេះកើតមាន និងនៅជាប់ជាមួយយើងតាំងពីដើមរៀងមក។ ប៉ុន្តែបើនិយាយពីប្រវត្តិ ខ្លឹមសារស៊ីជម្រៅ និងរបៀបត្បាញក្រមា គឺជារឿងមួយដោយឡែក និងស្មុគស្មាញ ហើយតម្រូវឲ្យមានការសិក្សាស្រាវជ្រាវវែងឆ្ងាយបន្តិច។ យ៉ាងណាក៏ដោយ សង្គមខ្មែរចាត់ទុកក្រមាជារបស់សំខាន់ស្ទើរខ្វះពុំបានក្នុងសកម្មភាព និងការរស់នៅប្រចាំថ្ងៃ។ វាមានសណ្ឋានត្រឹមតែជាសំពត់មួយផ្ទាំងប៉ុណ្ណោះ តែវាបានភ្ជាប់នូវតម្លៃ ខ្លឹមសារអត្តសញ្ញាណ និងទិដ្ឋភាពវប្បធម៌ក្នុងនោះមិនលែង។ ក្នុងជីវភាពប្រចាំថ្ងៃ វាមានតម្លៃដោយឡែកសម្រាប់កសិករ កម្មករ និងប្រជាពលរដ្ឋប្រើប្រាស់ ស្លៀកដណ្ដប់ វេចខ្ចប់ ក្រាល ទទូរ និងសម្រាប់លក់ដូរដោះស្រាយជីវភាព។ ក្នុងបរិបទប្រពៃណីទំនៀមទម្លាប់និងវប្បធម៌ ក្រមាជាផ្ទាំងសំពត់យ៉ាងវិសេសប្រើជាហូរហែក្នុងពិធីអាពាហ៍ពិពាហ៍ ពិធីបុណ្យ សម្រាប់ច្នៃលេងក្នុងល្បែងប្រជាប្រិយ និងជាអត្តសញ្ញាណជាតិដែលយើងពុំអាចបំភ្លេចបាន។ ចំណែកការនិយមក្នុងសម័យទំនើប ក្រមាជាវត្ថុអនុស្សាវរីយ៍មួយយ៉ាងល្អ និងសមរម្យសម្រាប់ជូនគ្នាទៅវិញទៅមក ជារបស់តាំងលម្អ ឬជាវត្ថុធាតុសម្រាប់ច្នៃជាសម្លៀកបំពាក់ ឬរបស់ប្រើប្រាស់ផ្សេងៗជាដើម។ គុណតម្លៃយ៉ាងពិសេសនេះហើយ ជាអ្វីដែលយើងត្រូវសិក្សាស្រាវជ្រាវ ឈ្វេងយល់ និងថែរក្សាឲ្យបានស្ថិតស្ថេរគង់វង្ស។ ហេតុដូច្នេះក្នុងអត្ថបទដ៏ខ្លីនេះ យើងនឹងព្យាយាមសង្ខេបអំពីប្រវត្តិខ្លះៗទាក់ទងនឹងការត្បាញរវៃជាទូទៅ ការត្បាញក្រមា រួមទាំងខ្លឹមសាររបស់វាក្នុងសង្គមវប្បធម៌ខ្មែរ។ ប៉ុន្តែដោយយោងលើពេលវេលាពុំមានច្រើន យើងសូមផ្អែកសេចក្ដីពិគ្រោះភាគច្រើននៃអត្ថបទនេះ លើឯកសារសារណាដែលសិក្សាស្រាវជ្រាវអំពី “តម្បាញក្រមាខ្មែរ” សរសេរដោយ ជា ពិសី (ជា ពិសី, ១៩៩៤)។

## ២. ភស្តុតាងនិងប្រវត្តិនៃការត្បាញរវៃក្នុងសង្គមខ្មែរ

ក្រមា គឺជាផលិតផលដែលបានមកពីការត្បាញរវៃ កែច្នៃចេញពីវត្ថុធាតុដើមផ្សេងៗមានដូចជាកប្បាសឬសូត្រ និងល័ក្តសម្រាប់ជ្រលក់ពណ៌ជាអាទិ៍។ តាំងពីដើមរៀងមក ខ្នារអំបោះ ក្ដារមូរ ធ្មេញឈើ ត្រល់ និងកីជាដើម សុទ្ធសឹងជាសម្ភារៈចាំបាច់បន្ថែមទៀតដែលត្រូវប្រើក្នុងការងារ តម្បាញ។ បើយោងតាមភស្តុតាងប្រវត្តិសាស្ត្រ គេបានរកឃើញសំណល់ក្បាលត្រល់ និងខ្នារអំបោះនៅស្ថានីយបុរាណវិទ្យាម្លូព្រៃ ស្ថិតក្នុងខេត្តព្រះវិហារ មានអាយុកាលប្រមាណ២០០ឆ្នាំមុនគ្រិស្តសករាជ។ តឹកតាងខាងលើអាចបញ្ជាក់បានថា មនុស្សរស់នៅលើទឹកដីនេះចេះត្បាញរវៃតាំងពីជាង២២០០ឆ្នាំមុន។

ដូចគ្នានេះដែរ បើផ្អែកលើការសិក្សាសិលាចារឹក គេឃើញមានសិលាចារឹកមួយចំនួនមានពាក្យនាំឲ្យយើងអាចពិចារណាបាន អំពីភស្តុតាងនៃការត្បាញរវៃក្នុងសម័យប្រវត្តិសាស្ត្រ។ តាមរយៈសិលាចារឹកវត្តសសរ១០០ (K.124) ចារក្នុងសតវត្សទី៩ គេឃើញមានពាក្យ “ក្របាស” [krapās] ក្នុង

បន្ទាត់ទី១៦ និងបន្ទាត់ទី១៩ (Cœdèse, 1951, IC.III.p.172)។ ចំណែកសិលាចារឹកទ្វារក្ដី ឬហៅថាទ្វារប្រាំបី (K.165) ចារក្នុងសតវត្សទី១០ ក៏ឃើញមានពាក្យថា "ក្របាស" [krapās] នៅបន្ទាត់ទី២៨ និងបន្ទាត់ទី៣១ ដែរ (Cœdès, 1954, IC.VI,p.135)។ ពាក្យទាំងនេះ ត្រូវបានអ្នកស្រាវជ្រាវសន្និដ្ឋានថាជាពាក្យពោលសំដៅហៅឈ្មោះ "កប្បាស" រុក្ខជាតិដែលជាវត្ថុធាតុសម្រាប់ប្រើក្នុងការត្បាញវៃជាប្រាកដ ដ្បិតអត្ថន័យជារួមក្នុងសិលាចារឹកទាំងពីរ និយាយពីការថ្វាយរបស់របរផ្សេងៗដល់ប្រាសាទសម្រាប់ប្រើប្រាស់ រួមទាំងខ្ញុំបម្រើប្រុសស្រីផងដែរ។

ឆ្លងមកដល់រវាងសតវត្សទី១១ គេឃើញមានពាក្យ "តៃថ្ករ" [tai thkar] ចារក្នុងសិលាចារឹកប្រាសាទស្ទឹងខាងកើត(K.879)ក្នុងបន្ទាត់ទី៨ និង១៩ (Cœdès,1942: IC.II,p.236)។ រីឯសិលាចារឹកគោករកា (K.155) ត្រង់បន្ទាត់ទី៩ និង២៦ មានពាក្យ "រង្វៃ" [raṅhvai] (Cœdès, 1953: IC.V,p.66-67) ហើយសិលាចារឹកព្រៃមៀន (K.18) នៅបន្ទាត់ទី៩ មានពាក្យ "កុ ត្បាញ" [ku tpāñ] (Cœdès, 1942: IC.II, p.146) និងសិលាចារឹកប្រាសាទស្ទុង(K.584) នៅបន្ទាត់ទី១២ មានពាក្យ "តៃ ថ្ការ (ថ្ករ?)" [tai thkār] (Cœdès, 1951: IC.III, p.127)។ តាមរយៈពាក្យទាំងនេះ គេអាចសន្និដ្ឋានបានថា ក្នុងសម័យកាលនោះ ការត្បាញវៃ គឺកើតមានជាប្រាកដក្នុងសង្គមខ្មែរ ដ្បិតមានឈ្មោះមនុស្សប្រុសស្រីជាច្រើនដែលទទួលភារៈកាន់ការទាំងនោះ ដូចមានភស្តុតាងក្នុងសិលាចារឹកខាងលើស្រាប់។

ចំណែកនៅចុងសតវត្សទី១៣ បើតាមកំណត់ហេតុលោក ជីវ តាក្វាន់ និយាយអំពីសម្លៀកបំពាក់ឲ្យដឹងថា អ្នកស្រុកខ្មែរតាំងពីស្ដេចដល់រាស្ត្រទាំងប្រុសស្រីសុទ្ធតែលែងខ្លួនទទេ មានតែសំពត់មួយផ្ទាំងតូចវណ្ឌជុំវិញខ្លួនរបៀបចងពុង ហើយបើត្រូវចេញទៅណា គេយកសំពត់មួយផ្ទាំងទៀតធំជាងមុនមករុំថែមពីលើ។ គេបញ្ជាក់ថា ការស្លៀកពាក់នេះក៏មានបែបបទតាមឋានៈផងដែរ (ជីវ តាក្វាន់, [បកប្រែដោយ លី ធាមតេង, ១៩៧៣])។ ប៉ុន្តែទោះជាបែបណាក្ដី តាមរយៈសេចក្ដីក្នុងកំណត់ហេតុអ្នកការទូតចិននេះ នាំឲ្យយើងដឹងថា ការត្បាញវៃក្រណាត់ផ្សេងៗសម្រាប់ស្លៀកពាក់ក្នុងសង្គមខ្មែរគ្រានោះ គឺចាប់ផ្ដើមរីកចម្រើនជាងមុនច្រើនណាស់ទៅហើយ បើទោះជាតាមទម្លាប់ស្រុកទេសគ្រានោះនិយមលែងខ្លួនទទេក៏ដោយ។ មិនតែប៉ុណ្ណោះសោត បើយោងតាមចម្លាក់នៅប្រាសាទនានាផងក៏សឹងឃើញថាខ្មែរមានក្រណាត់ច្នៃជាសម្លៀកបំពាក់ពេញបរិបូរណ៍។ ដូច្នេះគេជឿថា ក្រមាដែលយើងប្រើប្រាស់មកដល់សព្វថ្ងៃ ក៏កើតមានតាំងតែអំពីបុរាណកាលនោះដែរ បើទោះណាគេពុំទាន់រកប្រភពពាក្យ "ក្រមា" ឃើញច្បាស់លាស់នៅឡើយក្ដី ហើយជារឿយៗខ្មែរក៏ហៅវត្ថុនេះផ្សេងៗគ្នាតាមតំបន់ដែរដូចជា "ក្រមា" "កន្សែង" និង "ឈ្នួត" ជាដើម។

## ៣. របៀបត្បាញក្រមា

យើងពុំទាន់ឃើញមានភស្តុតាងឡើយ អំពីរបៀបត្បាញរវៃនៅសម័យបុរេប្រវត្តិ ឬក្នុងសម័យប្រវត្តិសាស្ត្ររាប់រយឆ្នាំមុន។ ប៉ុន្តែបើតាមការស្រាវជ្រាវ និងសង្កេតរបៀបនៃការត្បាញរវៃក្នុងសង្គមខ្មែរសម័យបច្ចុប្បន្ន គឺអាចធ្វើឡើងតាមពីរបែប ពោលគឺតាមបែបប្រពៃណី និងតាមបែបសម័យទំនើប។ ការត្បាញតាមបែបទំនើប ពុំសូវមានភាពស្មុគ្រស្មាញឡើយ ដ្បិតទាំងសម្ភារៈ និងវត្ថុធាតុសម្រាប់ប្រើក្នុងការងារតម្បាញ រួមទាំងសូត្រ និងល័ក្តជង ច្រើនជារបស់នាំចូលស្រាប់ៗពីប្រទេសជិតខាង។ ប៉ុន្តែចំពោះការត្បាញតាមបែបប្រពៃណី គឺមានដំណាក់កាលស្មុគ្រស្មាញច្រើន ហើយសម្ភារៈនិងវត្ថុធាតុប្រើសម្រាប់កាត្បាញ សុទ្ធតែច្នៃបង្កើតដោយសិប្បករផ្ទាល់។ ការងារនោះហាក់បង្ហាញពីចំណេះ គំនិតច្នៃប្រឌិត និងការអត់ធ្មត់ខ្ពស់របស់សិប្បករនីមួយៗ ទម្រាំសម្រេចបានក្រមាមួយសម្រាប់លក់ដូរ ឬប្រើប្រាស់។ ដោយហេតុដូច្នេះ ក្នុងចំណុចនេះយើងសូមលើកតែរបៀបត្បាញក្រមាតាមបែបប្រពៃណីមកបង្ហាញប៉ុណ្ណោះ ហើយរបៀបដែលលើកមកបង្ហាញខាងក្រោមនេះសោត គឺការត្បាញក្រមាពីអំបោះ។ ចំពោះការត្បាញអំពីសូត្រ ដែលមានបច្ចេកទេស និងបែបផែនដោយឡែកផ្សេង យើងសូមទុកមួយអន្លើ។

ជាទូទៅ ការត្បាញក្រមាតាមបែបប្រពៃណី ត្រូវឆ្លងកាត់ដំណាក់កាលច្រើន ក្រោយពីបានបេះកប្បាសប្រមូលពីចម្ការរួច ហើយបើនិយាយរៀបរាប់ក៏សឹងមានពាក្យបច្ចេកទេសច្រើន និងពិបាកយល់ដែរ។ ប៉ុន្តែយ៉ាងណាក៏ដោយ ដំណាក់កាលទាំងនោះរាប់តាំងពីបោះកប្បាស ផ្ដេច មូរសំឡី រវៃអំបោះ កុងអំបោះ ជ្រលក់ល័ក្ត ឲ្យបាយ អន្ទង ថ្ការ និងត្បាញជាដំណាក់កាលចុងក្រោយដែលនាំឲ្យកើតបានជាក្រមា។

"បោះកប្បាស" ជាការបោះកប្បាសយកមកហាស ដោយបោះប្រលេះយកគ្រាប់ រួចរក្សាកប្បាសនោះទុកមួយអន្លើ។ បន្ទាប់មក គេយករំពាត់មកវាយកប្បាសនោះឲ្យបែកសាច់ ដែលដំណាក់កាលនេះហៅថា "ផ្ដេច"។ ផុតពីនោះទៅ គឺគេយកអំបោះដែលផ្ដេចរួចមកមូរស្ដើងៗជាបន្ទះសំប៉ែតៗទំហំប៉ុនបាតដៃទុកសម្រាប់រវៃ។ ការងារក្នុងដំណាក់កាលនេះ គេហៅថា "មូរសំឡី"។ ក្រោយពេលមូរសំឡីបានហើយ គេយកសំឡីនោះទៅរវៃហូតជាសរសៃអំបោះ។ ប្រដាប់សម្រាប់រវៃហូតកប្បាសឲ្យកើតជាសរសៃអំបោះនេះ គេហៅថារហាត់រវៃ ហើយធ្វើពីឈើ និងឫស្សី។ ការរវៃអំបោះនេះសោត គឺមានភាពស្មុគស្មាញបន្តិចទម្រាំច្នៃបានពីភាពជាសំឡីទៅជាសរសៃអំបោះ។ ពេលបានជាសរសៃអំបោះរួចហើយ គេត្រូវយកអំបោះនោះទៅ "កុង" ឬហៅម្យ៉ាងទៀតថា "រងើង" ជាដុំៗ ដោយដាក់រហាត់កុង ដើម្បីធ្វើអំបោះឲ្យចេញជាចង្វាយៗ សម្រាប់យកទៅក្អួតទឹក និងជ្រលក់ល័ក្តយកពណ៌នៅដំណាក់កាលបន្ទាប់។

"ការជ្រលក់ល័ក្ត" ជាដំណាក់កាលសំខាន់នៃការផ្សារតម្បាញ ដ្បិតគេត្រូវមានចំណេះច្នៃល័ក្ត ធ្វើពណ៌ និងត្រូវចេះបច្ចេកទេសជ្រលក់ផង។ ជាធម្មតា គេចាត់ទុកពណ៌ដែលល្អក្នុងការផ្សារតម្បាញ គឺពណ៌បានពីល័ក្តធម្មជាតិ ហើយពណ៌នោះជាប់បានយូរ និងស្អាតជាងពណ៌ល័ក្តគីមី។ ល័ក្តធម្មជាតិ អាចច្នៃបានពណ៌ផ្សេងៗ តែគេចែកជាពណ៌មេមាន៤គឺ ក្រហម លឿង ខៀវ និងខ្មៅ។

ពណ៌ក្រហម បានពីខ្លឹមដើមស្បែង គ្រាប់ជម្ពូ (គ្រាប់សម្រាប់ជ្រលក់សូត្រឬជម្ពូគ្រឿងការី)។ ពណ៌ក្រហមស្រស់ បានពីក្រមរល័ក្ត ឬល័ក្តជុំក្រឡង់។ ពណ៌ក្រហមស្រាល បានពីសម្បកដើមឈើទាល។ ពណ៌ក្រហមជាំ បានពីសម្បកដើមស្មៅ។ ពណ៌ក្រហមប្រមឹក បានពីសម្បកដើមកណ្តោល។ ពណ៌ក្រហមប្រផេះ បានពីសម្បកដើមស្មាច់ និងពណ៌ក្រហមក្រមៅ បានពីសម្បកដើមធ្នង់ និងដើមពង្រ។

ពណ៌លឿង បានពីមើមព្រះអង្កោល និងមើមរមៀត (បុកលាយទឹក)។ ពណ៌លឿងទុំ បានពីសម្បកដើមព្រហូត។ ពណ៌លឿងខ្ចីបានពីសម្បកដើមពោធិ៍ ដើមខ្នុរ ដើមចង្រៀក ដើមដកព ដើមសង្កែ ដើមអំពិលបារាំង ដើមអញ្ចេ។

ពណ៌ខៀវ បានពីដើម និងស្លឹកត្រុំស្រស់។ ប៉ុន្តែវត្ថុធាតុនេះ អាចប្រែប្រួលទៅជាពណ៌ខៀវចាស់ ឬបៃតង អាស្រ័យលើរយៈពេលត្រាំទឹក។ ប្រសិនបើត្រាំមួយយប់ គឺបានពណ៌បៃតងខ្ចី តែបើត្រាំចាប់ពី២ យប់ឡើងទៅ នឹងបានពណ៌ខៀវ។ ចំពោះពណ៌ខៀវ គេអាចប្រើស្លឹកម្ទេស ស្លឹកវល្លិបាស ឬស្លឹកអំពិលក៏បាន។

ពណ៌ខ្មៅ បានពីស្លឹកដើមគ្រស់ ស្លឹកដើមក្ឋស ផ្លែពុល ខ្លុញ (មក្លឿ)។ ប៉ុន្តែដើម្បីបានពណ៌ខ្មៅល្អ គេត្រូវយកសូត្រ ឬសំពត់ដែលត្រូវជ្រលក់នោះទៅជ្រលក់ពណ៌បៃតងឲ្យឆ្អែត រួចហាលឲ្យស្ងួត ទើបជ្រលក់ពណ៌ខ្មៅជាក្រោយ (ជា ណារិន, ជា សោភារី, កែម សុនីន, ព្រាប ចាន់ម៉ារ៉ា, ២០០៣)។ ដោយឡែកចំពោះពណ៌ផ្សេងៗទៀត គេក៏អាចច្នៃពីដើមរុក្ខជាតិផ្សេងទៀតបានដែរ។

ចំពោះអំបោះដែលត្រូវជ្រលក់ គឺត្រូវយកទៅត្រាំទឹកធម្មតាមួយយប់សិន។ លុះព្រឹកឡើងទើបគេក្តួតអំបោះនោះទាល់តែស្ងួតទឹក ហើយទុកមួយអន្លើ រួចត្របែងវាជាដុំៗសណ្ឋានដូចអាចម៍ដង្កូវ ដើម្បីងាយស្រួលជ្រលក់។ តាមបុរាណ ពណ៌ដែលតែងប្រើជ្រលក់អំបោះមានមិនច្រើនឡើយ ពោលគឺច្រើនឃើញមានតែពណ៌ខៀវក្រមៅ និងពណ៌សប៉ុណ្ណោះ។ ហេតុដូច្នេះហើយ ទើបក្រមាជំនាន់នោះក៏តែងឃើញមានមិនច្រើនពណ៌ដែរ។ ប៉ុន្តែបច្ចុប្បន្ន គេអាចធ្វើក្រមាបានច្រើនពណ៌ជាងមុន ដ្បិតគេប្រើល័ក្តគីមីដែលមានច្រើនពណ៌។

បន្ទាប់ពីជ្រលក់អំបោះរួចហើយ គឺឈានដល់ដំណាក់កាលមួយទៀតហៅថា "ឲ្យបាយ"។ ឲ្យបាយគឺធ្វើអំបោះនៅឲ្យស្វិតល្អលែងផុយដូចកាលនៅឆៅហើយអាចប្រើការបានច្រើនមុខ។ វិធីធ្វើ គឺយកអំបោះត្រាំទឹកបាយ ឬទឹកដែលត្រាំសាច់បាយលាយទឹកឲ្យជ្រាយដូចបបរ ហើយចំហុយទាល់តែ

អំបោះស្វិត។ តំណក្រោយមក ក្នុងដំណាក់កាលនេះគេអាចយកអង្ករកិនជាម្សៅ ហើយចាក់ទឹកត្រាំនិងលាយវត្ថុធាតុផ្សេងៗទៀតប្រើជំនួសបាយវិញ។

ផុតពីឲ្យបាយអំបោះរួចហើយ គឺចូលដល់ដំណាក់កាល "អន្ទង"។ ការអន្ទងនេះ គឺដើម្បីបែងចែកសរសៃអំបោះរៀបលើធ្មេញឈើតាមពណ៌ ត្រៀមសម្រាប់ត្បាញ។ ការងារក្នុងដំណាក់កាលនេះត្រូវចំណាយពេលច្រើនថ្ងៃ ហើយត្រូវការមានមនុស្សជួយដៃជើងច្រើននាក់ដែរ។

ពេលអន្ទងអំបោះរួច គឺចូលដំណាក់កាលមួយទៀតហៅថា "ថ្ករ"។ ការថ្ករ គឺថ្ករលើកី បន្ទាប់ពីលើកអំបោះដាក់កីរៀបចំរួច ដោយយកឈើជាមសំប៉ែតមកស៊កចន្លោះធ្មេញឈើលើ និងក្រោមសរសៃអំបោះបែងឲ្យចេញជាគោមក្រឡា។ ជាធម្មតា គោមក្រឡាក្រមាខ្មែរមាន៥បែបគឺ ក្រឡាតូចល្មមបួនជ្រុងស្មើឬហៅថាក្រឡាចត្រង្គ ក្រឡាបួនជ្រុងទ្រវែងឬហៅថាក្រឡាថ្នាំងអំពៅ ក្រឡាកាត់ឬហៅថាក្រឡាភ្លោះ ក្រឡាកញ្ចក់ និងក្រឡាស្រកាលេញ។

ក្រោយពីថ្ករអំបោះចប់សព្វគ្រប់ហើយ ជាដំណាក់កាលចុងក្រោយហៅថា "ត្បាញ"។ ត្បាញនេះ គឺធ្វើឡើងនៅលើកី។ តាមឯកសារ កីបុរាណមានប្រវែងប្រមាណ៤ ទៅ៥ម៉ែត្រ ហើយជាទូទៅគេមានឆ្លាក់ក្បូរក្បាច់រចនាយ៉ាងវិចិត្រលើរបស់មួយនេះ រហូតឆ្លាក់ក្បាច់ដល់ទាំងត្រល់ផង។ ជាក់ស្ដែងដូចយើងឃើញកីបុរាណដាក់តាំងនៅសារមន្ទីរជាតិស្រាប់។ ដោយឡែក កីបច្ចុប្បន្នគឺមានប្រវែងប្រហែល២ ម៉ែត្រប៉ុណ្ណោះ។ ក្នុងដំណាក់កាលត្បាញនេះ "ត្រល់" ក៏ជារបស់សំខាន់ដែរ ដ្បិតវាប្រើសម្រាប់បោះនាំសរសៃសូត្រម្ដងមួយសរសៃៗ បង្កើតបានជាក្រមា។ ត្រល់នេះ មានរាងប្រហាក់ប្រហែលទូក ហើយខាត់យ៉ាងរលោង ដើម្បីងាយស្រួលបោះនាំសរសៃសូត្រក្នុងពេលត្បាញ។ ទាក់ទងនឹងត្រល់នេះ សិប្បករចាស់ៗមានពាក្យបណ្ដៅថា "កូនអូរតូចមួយបងឆ្លងមិនរួច សំពៅ [ទូក] នាងពៅឆ្លងទៅឆ្លងមក"។

## ៤. ក្រមាក្នុងបរិបទវប្បធម៌ និងការប្រើប្រាស់

ជាទូទៅ ក្រមាដែលត្បាញក្នុងសង្គមខ្មែរមានពីរប្រភេទ គឺក្រមាអំបោះ និងក្រមាសូត្រ។ ក្រមាអំបោះ ត្បាញពីសរសៃអំបោះដែលហូតពីកប្បាសដូចរៀបរាប់ខាងលើ។ រីឯក្រមាសូត្រ គឺត្បាញពីសរសៃសូត្រដែលបានពីដង្កូវនាង។ បើតាមសង្កេត រវាងក្រមាទាំងពីរបែបនេះ ខ្មែរយើងតែងប្រើក្រមាអំបោះក្នុងសកម្មភាពប្រចាំថ្ងៃច្រើនជាងក្រមាសូត្រ ដ្បិតក្រមាប្រភេទនេះងាយថែទាំ និងបោកគក់។ ចំពោះក្រមាសូត្រ គេច្រើនឃើញប្រើម្ដងម្កាលពេលមានពិធីបុណ្យផ្សេងៗ ឬគ្រាន់តែជាវត្ថុលម្អប៉ុណ្ណោះ ហើយសព្វថ្ងៃគេនិយមយកក្រមាសូត្រធ្វើជាវត្ថុអនុស្សាវរីយ៍សម្រាប់ជូនគ្នាទៅវិញទៅមកផងក៏មាន។ ក្រមាប្រភេទនេះ មិនអាចបោកសម្អាតបានញឹកញាប់ដូចក្រមាអំបោះឡើយ ព្រោះសាច់សូត្រអាចរួញនិងរហែក ឬដាច់ ប្រសិនបើត្រូវទឹកញឹកញាប់ពេក។ ប៉ុន្តែទោះជាបែបណាក្ដី ប្រសិនបើគេសម្លឹងមើលក្រមាខ្មែរក្នុងបរិបទវប្បធម៌និងការប្រើប្រាស់ ក្រមាបានបង្ហាញនូវអត្តសញ្ញាណ និង

ប្រយោជន៍យ៉ាងច្រើនក្រៃលែងចំពោះជនជាតិខ្មែរ ដូចមាននិយាយក្នុងខ្លឹមសារកំណាព្យលោកព្រហ្ម ម៉ាញ។ ចំពោះក្នុងន័យជារបស់ប្រើប្រាស់ធម្មតាប្រចាំថ្ងៃ ក្រមាអាចធ្វើជាសំពត់ស្លៀកដណ្ដប់ វេចខ្ចប់ ទទូរ និងក្រាលជាកម្រាលក៏បាន។ នៅតាមស្រុកស្រែចម្ការប្រុសៗវ័យកណ្ដាលច្រើនយកក្រមាធ្វើជា សំពត់ស្លៀកនៅផ្ទះ ឬផ្លាស់ងូត។ បើស្ត្រីចំណាស់ៗ ក៏ច្រើនយកក្រមាចងពុងនៅផ្ទះ ឬផ្លាស់ងូតទឹក ដែរ។ ក្នុងសម័យបុរាណ គេតែងឃើញស្ត្រីខ្មែរយកក្រមាចងពុងលើអាវបំពង់មួយជាន់ទៀត ពេលគេ ចេញទៅណាជិតឆ្ងាយ ឬធ្វើការផ្សេងៗ។ រីឯបុរស ច្រើនយកក្រមាក្រវ៉ាត់ចង្កេះ។ ដោយឡែក ចំពោះ ក្មេងៗ គេច្រើនយកក្រមាចងធ្វើអង្រឹមឬហៅថាពាតបាឲ្យក្រោយពេលងូតទឹករួច ឬពេលនៅផ្ទះ។ ម្យ៉ាងទៀត គេក៏អាចយកក្រមាចងធ្វើអាវពាក់បណ្ដោះអាសន្ន ឬនៅផ្ទះបានដែរ ដោយគ្រាន់តែបត់ ក្រមាជាពីរ ហើយចងចុងជាយសងខាងភ្ជាប់គ្នាខាងលើនិងខាងក្រោម បានជាទម្រង់ស្ទើរដូចថង់។ គេ យកផ្នែកម្ខាងដែលចំហ មកចងជាយភ្ជាប់គ្នានៅត្រង់មួយភាគបីនៃផ្នែកម្ខាងដែលចំហនោះជាពីរ ចំណុច ដើម្បីធ្វើជាក និងដៃអាវទាំងពីរ។ អាវបែបនេះ ច្រើនសម្រាប់ក្មេងប្រុស។ លើសពីនេះ ក្រមា អាចប្រើធ្វើជាសំពត់ជូតខ្លួន ជូតមុខ ក្រោយងូតទឹករួច ឬពេលធ្វើការបែកញើសបានយ៉ាងងាយ។

ចំណែកឯការប្រើប្រាស់ក្នុងរូបភាពផ្សេងទៀត ក្រមាអាចធ្វើជាសំពត់ដណ្ដប់ជំនួសភួយបាន មួងម្កាល ឬធ្វើជាកម្រាលសម្រាប់អង្គុយ ឬដេកលេងបាន។ មិនតែប៉ុណ្ណោះ បើក្រមាធំ គេអាចយកធ្វើ ជាអង្រឹងសម្រាប់ក្មេងដេកផងក៏បាន ហើយវាក៏អាចប្រើសម្រាប់ទទូរ ឬធ្វើជាឈ្នួតក្នុងពេលធ្វើដំណើរ ជិតឆ្ងាយបានដែរ។ បន្ថែមពីនេះ ចំពោះការប្រើប្រាស់ក្នុងការងារទូលរែកវេចខ្ចប់វិញ ក្រមាអាចធ្វើជា "រងើ្វល" ទ្រាប់ទូលរបស់ផ្សេងៗ ឬអាចធ្វើជា "សម្ពាយ" ឬ "បង្វេច" ឬអាចចងធ្វើជា "បាវ" ឬ "ការុង" ឬ "ថ្នក់" ដាក់របស់របរតូចធំធូន់ស្រាលតាមចំណេះច្នៃបាន។ មួយវិញទៀត គេក៏អាចយកក្រមាសម្រាប់ ចងរឹតជំនួសខ្សែរម្ដងម្កាលបានដូចជាចងឧស ឬចងបាច់អំពៅជាដើម។

ចំពោះការប្រើក្រមាក្នុងទំនៀមនិងជារបស់លម្អវិញ ខ្មែរយើងតែងប្រើក្រមាសម្រាប់បង់ក ឬ ពានា ដែលភាគច្រើនជាទម្លាប់របស់ចាស់ទុំតាមស្រុកស្រែចម្ការ ពេលទៅបុណ្យទាន ឬទៅវត្ត ជាដើម។ មិនតែប៉ុណ្ណោះ គេក៏តែងឃើញចាស់ៗយកក្រមាទៅក្រាលគ្រែទេសនាផងដែរ ដោយពួក គាត់យល់ថា នេះជាអានិសង្ឃមួយក្នុងការបូជាធម្មទេសនា។ រីឯក្នុងពិធីមង្គលការ គេប្រើក្រមាស ម្រាប់រុំបាយព្រលឹង ខ្ចប់ស្លា (ស្លាដក់-ស្លាកន្សែង) និងរុំផ្កាស្លាជាដើម។ ចំណែកការប្រើក្រមាក្នុងល្បែង ប្រជាប្រិយវិញ គេតែងប្រើវាសម្រាប់មូរធ្វើឈូង ចងលេងលាក់កន្សែង ចងមុខវាយក្អម និងរាំវង់ក្តាំង ។ល។ មិនតែប៉ុណ្ណោះ នៅឆ្នាំ២០០១ ក្រមាបានបង្កើតជារបាំ និងសម្ដែងជាផ្លូវការក្នុងទិវាវប្បធម៌ជាតិ ៣ មីនា ឆ្នាំ២០០២ ហើយរបាំនេះបានទាំងបញ្ចូលក្នុងកម្មវិធីសិក្សាមហាវិទ្យាល័យនាដសាស្ត្រឲ្យ សិស្សសិក្សារហូតដល់សព្វថ្ងៃ។

ដោយក្រមាតែងស្ថិតក្នុងផ្នត់គំនិតខ្មែរ ក្នុងវិស័យកីឡាគុនល្បុក្កតោ គេបានកំណត់យកក្រមាសម្រាប់ជាគ្រឿងសម្គាល់កម្រិតសមត្ថភាព និងចំណេះដឹងក្បាច់គុនដូចជាក្រមាខ្មៅ និងក្រមាមាសជាដើម ដ្បិតក្នុងស្បៀត ឬមេគុននៃក្បាច់គុននេះក៏មានប្រើក្រមាដែរ។ មិនតែប៉ុណ្ណោះ ថ្មីៗនេះសិល្បករខ្មែរមួយចំនួន បានយកក្រមាធ្វើជាម៉ូតសម្លៀកបំពាក់ កាបូប ឬប្រើសម្រាប់ការបង្ហាញ និងសម្តែងក្នុងវិស័យរបស់គេយ៉ាងជោគជ័យនិងគួរឲ្យចាប់អារម្មណ៍។ ចំណែកនៅការិយាល័យ និងភោជនីយដ្ឋានទំនើបៗខ្លះ ថ្មៃក្រមាធ្វើជារនាំងបង្អួច ឬជាកម្រាលតុយ៉ាងស្រស់ស្អាត ដែលហាក់បង្ហាញពីការរាប់អានក្រមាក្នុងសង្គមទំនើប។ ដោយឡែក ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គេបានជ្រើសយកក្រមាសម្រាប់ចែកជូនកម្មាភិបាល កងទ័ព និងប្រជាជនទាំងក្មេងចាស់ប្រុសស្រីប្រើប្រាស់គ្រប់ៗគ្នា។ ប៉ុន្តែក្រមានោះ ជាក្រមាមានក្រឡាក្រហមលាយសតែមួយប្រភេទប៉ុណ្ណោះ ពុំមានក្រមាចម្រុះពណ៌ដូចសម័យផ្សេងៗឡើយ ហើយគេពុំដឹងថាវាមានអត្ថន័យអ្វីដែរក្នុងរបបនោះ (ជា ណារិន, ជា សោភារី, កែម សុនីន, ព្រាប ចាន់ម៉ារ៉ា, ២០០៣)។

## ៥.សេចក្តីសន្និដ្ឋាន

ក្រមា ពុំមែនជាវត្ថុសាមញ្ញឡើយក្នុងសង្គមប្រវត្តិសាស្ត្រ និងវប្បធម៌ខ្មែរ។ វាប្រហែលកើតឡើងដំណាលគ្នានឹងពេលដែលមនុស្សរស់លើទឹកដីនេះចេះត្បាញរវៃ តាំងពី២២០០ឆ្នាំមុនមកម្ល៉េះ ដ្បិតគេបានរកឃើញភស្តុតាងសម្ភារៈតម្បាញ តាំងពីក្នុងសម័យបុរេប្រវត្តិសាស្ត្រ។ ចំណែកសិលាចារឹកចារក្នុងរវាងសតវត្សទី៩ ដល់ទី១១ គេបានរកឃើញពាក្យពេចន៍មួយចំនួនទៀតពាក់ព័ន្ធនឹងការត្បាញ។ ជាក់ស្តែងដូចជាពាក្យ "ក្រុបាស" "តៃថ្កវ" និង "កុ ត្បាញ" ជាដើម។ ក្រុបាស ជាពាក្យដែលក្លាយមកជា "កប្បាស" ជារុក្ខជាតិសំខាន់ប្រើសម្រាប់ច្នៃធ្វើជាអំបោះនោះឯង។ ចំណែក តៃ ថ្កវ ឬ កុត្បាញ គឺជាមនុស្សស្រីបម្រើតាមប្រាសាទ ដែលទទួលភារៈជាអ្នកថ្កវអំបោះ និងត្បាញ។ ឈានដល់ចុងសតវត្សទី១៣ យើងបានដឹងកាន់តែច្បាស់ទៀត តាមរយៈកំណត់ហេតុលោកជីវតាក្វាន់ រៀបរាប់អំពីការស្លៀកពាក់របស់អ្នកស្រុកចេនឡា។ យើងដឹងថាពេលនោះ ការត្បាញរវៃរីកចម្រើនខ្លាំងជាងមុនឆ្ងាញទៅហើយ ព្រោះគេឃើញមានក្រណាត់ច្រើនប្រភេទ រហូតដល់មានក្រណាត់ធម្មតា និងក្រណាត់វិសេសសម្រាប់តែក្សត្រ ឬមន្ត្រីតាមឋានៈផ្សេងៗគ្នា។

ដោយឡែក ចំពោះទិដ្ឋភាពនៃការត្បាញក្រមាបែបប្រពៃណីវិញ ឃើញថាហាក់មានភាពស្មុគស្មាញ និងវែងឆ្ងាយណាស់។ ការងារនេះ ពិតជាត្រូវការមនុស្សហ្មត់ចត់ អត់ធ្មត់ និងមានចំណេះយល់ពីធម្មជាតិផង ទើបអាចធ្វើការការជាមួយសរសៃអំបោះដ៏តូចឆ្មារ ឲ្យកើតបានជាផ្ទាំងក្រមាដ៏ធំសម្រាប់ប្រើ រំលេចដោយក្រឡាគោម និងពណ៌យ៉ាងល្អវិសេស។ ចំពោះអត្ថប្រយោជន៍របស់ក្រមាក្នុងសង្គមខ្មែរវិញ គឺកាន់តែពិសេសជាងនោះទៅទៀត។ ខ្មែរចេះបង្កើត និងប្រើប្រាស់ក្រមាបានច្រើនសណ្ឋាន

ស្ទើររាប់មិនអស់ ក្នុងសកម្មភាពប្រចាំថ្ងៃ រាប់តាំងពីស្លៀកដណ្ដប់ វេចខ្ចប់ ទទូរ ក្រាល ស្លៀកពាក់ ។ល។ម្យ៉ាងវិញទៀត ក្រមាក៏មានខ្លឹមសារដោយឡែកមួយទៀតក្នុងបរិបទវប្បធម៌ និងប្រពៃណីផងដែរ ហើយរហូតវាបានក្លាយជានិមិត្តរូប និងអត្តសញ្ញាណជាតិយ៉ាងសំខាន់។ ប៉ុន្តែយ៉ាងណាក៏ដោយ មកដល់បច្ចុប្បន្ន ការផ្សារតម្បាញក្រមាហាក់ប្រឈមនឹងការបាត់បង់គួរឲ្យបារម្ភ ជាពិសេសការត្បាញតាមបែបប្រពៃណី។ សហគមន៍ខ្លះ បានបោះបង់ការត្បាញក្រមាចោលទាំងស្រុង ស្របពេលក្មេងជំនាន់ក្រោយហាក់មិនចាប់អារម្មណ៍នឹងក្រមា ហើយផលិតផលបរទេសដែលអាចប្រើជំនួសក្រមាជាច្រើនបាននាំចូលមក។ ចំណែកសហគមន៍ខ្លះ នៅបន្តត្បាញក្រមាតិចតួច តែពួកគេលែងចេះផលិតសម្ភារៈ និងវត្ថុធាតុសម្រាប់ត្បាញទៀតហើយ ដ្បិតរបស់ទាំងនេះមានស្រាប់ៗនាំចូលមកលក់លើទីផ្សារ។ ទាំងអស់នេះ ជាការប្រឈមដែលយើងមើលឃើញជាក់ស្ដែងសព្វថ្ងៃ ហើយដែលគួរតែមានការសិក្សានិងថែរក្សា ដ្បិតវាជាអត្តសញ្ញាណដ៏សំខាន់របស់ជាតិ និងវប្បធម៌៕


**ឯកសារយោង**

*ជា ពិសី*

១៩៩៤, *តម្បាញក្រមាខ្មែរ,* សារណាបញ្ចប់បរិញ្ញាបត្រ, មហាវិទ្យាល័យបុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

ជា ណារិន, ជា សោភារី, កែម សុនីន, ព្រាប ចាន់ម៉ារ៉ា

២០០៣, *ស្លៀកពាក់និងថែរក្សាខ្លួនចុងសតវត្សទី១៩ ដល់សតវត្សទី២០,* រៃយំ, ភ្នំពេញ

ជីវ តាក្វាន់

១៩៧៣, *អំពីប្រពៃណីនៃអ្នកស្រុកចេនឡាន,* [លី ធាមតេង ប្រែសម្រួល], ភ្នំពេញ

Cœdès George

1942, *L’inscriptions du Cambodge,* Vol.II, EFEO, Paris

1951, *L’inscriptions du Cambodge,* Vol.III, EFEO, Paris

1953, *L’inscriptions du Cambodge,* Vol.V, EFEO, Paris

1954, *L’inscriptions du Cambodge,* Vol.VI, EFEO, Paris